# ប្រធានសមាគមកសិករ លោក ថេង សាវឿន និង សហការីពីរនាក់ ត្រូវបានឃាត់ខ្លួន




លោក ថេង សាវឿន ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)។

ភ្នំពេញ — លោក ថេង សាវឿន ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) និងសហការីរបស់លោកពីរនាក់ ត្រូវបានសមត្ថកិច្ចខេត្តក្រចេះ ឃាត់ខ្លួនកាលពីថ្ងៃពុធ ក្រោមការបញ្ជារបស់ស្នងការនគរបាលខេត្តរតនគិរី។

ការឃាត់ខ្លួននេះ ធ្វើឡើង ខណៈលោកនិងក្រុមការងារកំពុងធ្វើដំណើរមករាជធានីភ្នំពេញវិញ កាត់តាមខេត្តក្រចេះ កាលពីម៉ោងប្រមាណ ១១ព្រឹក ថ្ងៃពុធ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល និងការដើរលេងកម្សាន្តនៅក្នុងខេត្តរតនគិរី។ នេះបើតាមភរិយារបស់លោក ថេង សារឿន គឺអ្នកស្រី ញូង សុខហៀង និងមន្ត្រីសិទ្ធិមនុស្ស។

អ្នកស្រី ញូង សុខហៀង អាយុ ៣៣ ឆ្នាំ ប្រាប់វីអូអេនៅរសៀលថ្ងៃព្រហស្បតិ៍ថា កាលពីថ្ងៃទី ១៣ ដល់ ១៤ ខែឧសភា ឆ្នាំ ២០២៣ ស្វាមីរបស់អ្នកស្រីបាននាំគ្នាប្រជុំ ដើម្បីពង្រឹង ក៏ដូចជាកសាងសមត្ថភាពរបស់បុគ្គលិក និងវិភាគអភិក្រមសិទ្ធិជាមូលដ្ឋាន ដែលធ្វើឡើងនៅក្នុងខេត្តរតនគិរី។

អ្នកស្រី ញូង សុខហៀង ដែលធ្វើដំណើរទៅខេត្តជាមួយស្វាមីដែរ បន្តថា អាជ្ញាធរខេត្តក្រចេះមិនបានបញ្ជាក់ហេតុផលនៃការឃាត់ខ្លួនឡើយ ខណៈពួកគេកំពុងនៅតាមផ្លូវពីខេត្តរតនគិរីមកកាន់រាជធានីភ្នំពេញវិញ។

បើតាមភរិយា គិតត្រឹមរសៀលថ្ងៃព្រហស្បតិ៍ ស្វាមីរបស់អ្នកស្រី និងមិត្តរួមការងារពីរនាក់ទៀត រួមមាន លោក ញិល ភាព មន្ត្រីជាន់ខ្ពស់ចងក្រងនិងតស៊ូមតិ និងលោក ថាន់ ហាច មន្ត្រីចងក្រង ត្រូវបានបញ្ជូនទៅស្នងការខេត្តរតនគិរី។

អ្នកស្រីចាត់ទុកការឃាត់ខ្លួនស្វាមីថាជារឿងមិនសមហេតុផល។

អ្នកស្រីបញ្ជាក់ថា៖ «ចំពោះខ្ញុំជាគ្រួសារគិតថាជារឿងមួយដែលអត់ស័ក្តិសម ដោយសារថា ពួកខ្ញុំបានធ្វើកម្មវិធីនៅរតនគិរី ហើយនឹងដើរលេងខេត្តរតនគិរី រយៈពេល ៤ ថ្ងៃហើយ ប៉ុន្តែហេតុអ្វីពេលពួកខ្ញុំបានចេញដំណើរមកវិញ បានកាក់ឡានពួកខ្ញុំ។ ហើយតាមពិត ពួកខ្ញុំគ្រាន់តែទៅ Training (បណ្តុះបណ្តាល) ធ្វើការងារ ក្រុមគ្រួសារដើរលេងអីផងទេ»។

វីអូអេមិនទាន់អាចសុំការអត្ថាធិប្បាយពី លោក អ៊ូ សុបុណ្ណា ស្នងការនគរបាលខេត្តក្រចេះ និងលោក អ៊ុង សុភាព ស្នងការនគរបាលខេត្តរតនគិរីបាននៅឡើយទេ។

វីអូអេក៏មិនទាន់អាចសុំការអត្ថាធិប្បាយពី លោក ឆាយ គឹមខឿន អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិបានដែរ។

អ្នកនាំពាក្យសមាគមសិទ្ធិមនុស្សអាដហុក លោក ស៊ឹង សែនករុណា ដែលកំពុងតាមដានករណីឃាត់ខ្លួននេះ ប្រាប់វីអូអេថា សមត្ថកិច្ចនៅមិនទាន់អាចបញ្ជាក់មូលហេតុនៃការចាប់ខ្លួនពួកគេនោះទេ ខណៈអាជ្ញាធរក៏មិនអនុញ្ញាតឱ្យលោកនិងអ្នកឃ្លាំមើលផ្សេងទៀតចូលជួបលោក ថេង សារឿន និងសហការីរបស់លោកទាំងពីរនាក់។

បើតាមអ្នកនាំពាក្យរូបនេះ អាជ្ញាធរគួរផ្តល់សិទ្ធិសេរីភាពពេញលេញដល់អង្គការសង្គមស៊ីវិលក្នុងការបំពេញបេសកកម្មរបស់ពួកគេ ដោយហេតុថា កម្ពុជាគឺជាប្រទេសប្រជាធិបតេយ្យ។

លោកបញ្ជាក់ថា៖ «អ៊ីចឹងក្នុងករណីនេះ ខ្ញុំយល់ថា ដើម្បីឱ្យមានលម្ហនៃសេរីភាពខាងសង្គមស៊ីវិលឱ្យមានភាពល្អប្រសើរឡើង សមត្ថកិច្ចគួរតែមានការបើកចិត្តឱ្យទូលំទូលាយក្នុងការផ្តល់ឱកាសនិងលទ្ធភាព និងផ្តល់សិទ្ធិសេរីភាពពេញលេញទៅដល់ក្រុមអង្គការសង្គមស៊ីវិល ដើម្បីធ្វើកិច្ចការងាររបស់ខ្លួនក្នុងការបំពេញបេសកកម្មដើម្បីបម្រើទៅដល់ប្រជាកសិករ ក៏ដូចជាសង្គមជាតិយើងហ្នឹង»។

អ្នកនាំពាក្យរូបនេះអះអាងថា ការធ្វើវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពបុគ្គលិករបស់ខ្លួនជារឿងធម្មតានៃក្រុមអង្គការសង្គមស៊ីវិល។

អ្នកស្រី ចក់ សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លើកឡើងថា ការឃាត់ខ្លួនមេដឹកនាំសង្គមស៊ីវិល និងសហការី ជាសកម្មភាពធ្វើទុក្ខបុកម្នេញ និងគាបសង្កត់សិទ្ធិសេរីភាពនៅក្នុងការចងក្រងសហគមន៍នៅតាមតំបន់មូលដ្ឋាន។

អ្នកស្រីប្រាប់វីអូអេថា៖ «នេះជាការបំពានសេរីភាពមូលដ្ឋាន រាប់ទាំងសេរីភាពការជួបជុំដោយសន្តិវិធី ហើយនិងសេរីភាពខាងសមាគមផងដែរ ហើយការបន្តធ្វើបែបនេះបង្ហាញពីការមិនត្រឹមតែជាការបំពានទេ តែជាការធ្វើទុក្ខបុកម្នេញមកដល់អង្គការសង្គមស៊ីវិល ដូចដែលយើងដឹងហើយថា កម្ពុជាយើងនឹងធ្វើការបោះឆ្នោតនាពេលខាងមុខនេះ។ អ៊ីចឹងបរិយាកាសទាំងអស់នេះ វាប៉ះពាល់ដល់លម្ហសង្គមស៊ីវិល ដែលជាកត្តាមួយសំខាន់ក្នុងការកំណត់ថា ការបោះឆ្នោតប្រព្រឹត្តដោយសេរី និងយុត្តិធម៌ផងដែរ។

កាលពីដើមឆ្នាំ ២០១៤ លោក ថេង សាវឿន ធ្លាប់ត្រូវបានចាប់ឃុំខ្លួនក្នុងពន្ធនាគារ នៅក្នុងករណីបង្ក្រាបបាតុកម្មរបស់កម្មកររោងចក្រ នៅជាយរាជធានីភ្នំពេញ៕